**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា លើកទី៤

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និងនិយោជក ឱ្យបានជ្រាបថា កាលពីថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានបន្តកិច្ចប្រជុំលើកទី៤ របស់ខ្លួន ដើម្បីចរចាកំណត់ប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២០ ក្រោយពីភាគីកម្មករនិយោជិត និងភាគីនិយោជកបានប្រជុំពិភាក្សាផ្ទៃក្នុងរបស់ខ្លួនចំនួន ៣ដង។

ភាគីនីមួយៗបានបន្តប្រជុំពិភាក្សាយ៉ាងផុសផុល និងបានបង្ហាញនូវគោលជំហររបស់ខ្លួនជូនអង្គប្រជុំ ដោយភាគីកម្មករនិយោជិតបានបន្ថយពីតួលេខ ១៩៩ដុល្លារអាមេរិក មកត្រឹម ១៩៧ដុល្លារអាមេរិក និងភាគីនិយោជកបានដំឡើងពីតួលេខ ១៨៤ដុល្លារអាមេរិក ទៅ ១៨៤,៥ដុល្លារអាមេរិក ជាតួលេខប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២០។ ភាគីនីមួយៗបានឯកភាពបន្តប្រជុំពិភាក្សានៅរសៀលថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ៣រសៀល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និងនិយោជក មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩